គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរិធានបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរិធានបាលកិច្ច
Trust Regulator

លេខ ២៦ ចេញផ្សាយថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១
No. 26 Released on December 27, 2021

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

ការផ្តន្ទាទោសពិន័យជាប្រាក់ចំពោះបរិធានបាលដែលប្រព្រឹត្តល្មើស

Punishment in A Financial Fine for Trustees Who Commit Crimes

មាត្រា ៤៦ និង៤៧ នៃច្បាប់ស្តីពីបរិធានបាលកិច្ច (២០១៩) បានចែងថា បរិធានបាលដែលមានចេតនាផ្តល់ព័ត៌មានមិនពិតក្នុងការចុះបញ្ជីបរិធានដំបូងឬចុះបញ្ជីបរិធានបន្ត ស្របតាមបទ-ប្បញ្ញត្តិនៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀលទៅ ២០០ ០០០ ០០០ (ពីរយលាន) រៀល និង/ឬដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ៣ (បី) ឆ្នាំ។ បុគ្គលឬបរិធានបាលដែលចូលរួមប្រព្រឹត្តបទល្មើសទាក់ទងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដោយអនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញ-ប្បទានភេរវកម្ម និងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន។ បរិធានបាលដែលទម្លាយការសម្ងាត់វិជ្ជាជីវៈ ដែលបណ្តាលឱ្យខូចផលប្រយោជន៍ភាគីពាក់ព័ន្ធ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀលទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀលនិង/ឬដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ១ (មួយ) ឆ្នាំ (*ច្បាប់ស្តីពីបរិធានបាលកិច្ច, ២០១៩; ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១; អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ២០២១*)។

Article 46 and 47 of the Law on Trust (2019) states that A trustee who has intention to give a fake information in the initial trust registration or the trust re-registration in accordance with the provisions of this law shall be punished in a financial fine from 50,000,000 (fifty million) riels to 200,000,000 (two hundred million) riels and /or be imprisoned from 6 (six) months to 3 (three) years. Any person or Trustee who involves in committing any offence related to money laundering and financing of terrorism shall be punished in accordance with the Law on Anti-Money Laundering and Combatting Terrorism Financing and the criminal provisions in force. A trustee who breaches professional confidentiality causing damage to interest of the related parties shall be punished in a financial fine from 50,000,000 (fifty million) riels to 100,000,000 (one hundred million) riels and /or be imprisoned from 1 (one) month to 1 (one) year (*Law on Trust, 2019; Law on the Organization and Functioning of the Non-Bank Financial Services Authority (NBFSA), 2021; Sub-Decree on the Organization and Functioning of Units Under the NBFSA, 2021*).

ឯកសារយោង | References:

- មាត្រា ៤៦&៤៧, ច្បាប់ស្តីពីបរិធានបាលកិច្ច. (២០១៩).
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).

អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរិធានបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.